# ពិធីសំពះព្រះអាទិត្យក្នុងសង្គមខ្មែរ

ព្រះអាទិត្យគឺជាទេពដែលលេចឡើងដំបូងគេ ក្នុងអារ្យធម៌បុរាណអេហ្ស៊ីប និងតាមតំបន់ទន្លេឥណ្ឌា[១] រួចហើយសាយភាយមកតំបន់ខាងត្បូង និងអាស៊ីអាគ្នេយ៍តាមរយៈពាណិជ្ជករ និងបុព្វជិតសាសនា។ តាមជំនឿដើម ព្រះអាទិត្យឬព្រះសូរិយា ជាទេពដែលបង្កើតអ្វីលើលោក ឬភពផែនដី រួមមានមនុស្ស សត្វ រុក្ខជាតិ និងការរស់ទាំងឡាយ។[២] ដោយសារតែមានជំនឿបែបនេះ ទើបមនុស្សក្នុងសង្គមមួយចំនួន ពិសេសអ្នកគោរពលើព្រាហ្មណ៍សាសនា និងហិណ្ឌូសាសនា តែងតែប្រារព្វពិធីសំពះព្រះអាទិត្យ ជាការរំលឹកដល់គុណដែលទ្រង់បានបង្កើត និងទ្រទ្រង់ជិវិតនៅលើផែនដីនេះ។ ឥទ្ធិពលវប្បធម៌បែបនេះហាក់បីដូចជាមានឃើញខ្លះនៅក្នុងសង្គមខ្មែរ តែពុំសូវមានការចាប់អារម្មណ៍។

ក្នុងប្រពៃណីហិណ្ឌូ អ្នកគោរពលើព្រះអាទិត្យ និងមហេសីរបស់ព្រះអង្គ គឺព្រះនាងឧស (Usha) តែងបង្ហាញនូវការគោរព និងសុំនូវការប្រទានពរ ហើយពិធីនេះគឺធ្វើរយៈពេល៤ថ្ងៃ ដោយការផឹកទឹក ឈរក្នុងទឹករយៈពេលយូរ ការថ្វាយជផ្កាយ (ប្រាសាទ) និងអំគ្យ (រូបលេខ១-២) ដែលថ្ងៃនៃការប្រារព្ធនេះគេហៅថា បេហ្វ អំគ (pehla arghya) ឬ សអនធ្យ អំគ (saandhya arghya) ទៅដល់ការលិច និងរះរបស់ព្រះអាទិត្យ។[៣] ការបូជាមួយបែបទៀត គឺគេហៅថា **សូរិយានមស្ក** (ព្រះអាទិត្យ) ដែលមានន័យថាការវន្ទនាដល់ព្រះអាទិត្យបែបយោគ (Yoga) ដែលទាក់ទងទៅនឹងនិមិត្តរូបនៃព្រះអាទិត្យដែលជាដី និងប្រភពនៃជិវិតទាំងឡាយ។[៤] អ្នកគោរពបូជាជឿជាក់ថា កាំរស្មីរបស់ព្រះអាទិត្យមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការរស់មានជិវិតទាំងឡាយ។ ក្នុងគម្ពីរអថ៌វវេទ ព្រះអាទិត្យត្រូវបានគេជឿថាបានបំផ្លាញចោលនូវសេចក្តីស្លាប់ និងជំងឺទាំងឡាយ។[៥] ប្រពៃណីមួយទៀត គឺពិធីបូជាដល់បុព្វការីជន ដោយការសែនទឹកដល់បុព្វការីជននៅចំពោះមុខព្រះអាទិត្យរះនា

---

[១] W. J. Wilkins, (1882:25)

[២] សុខ កែវ សុវណ្ណាព៉, (២០២១)

[៣] https://www.dnaindia.com/india/photo-gallery-chhath-puja

[៤] https://en.wikipedia.org/wiki/Surya

[៥] https://www.indiatvnews.com/lifestyle/news-chhath

អត្ថបទដោយ៖ សុខ កែវ សុវណ្ណាព៉

ពេលព្រលឹម។[៦] ការពិតទៅ នៅឥណ្ឌា និងតំបន់ជិតខាងមួយចំនួនមានពិធីជាច្រើនដែលគេធ្វើឡើងដើម្បីគោរពដល់ព្រះសូរិយា ឬព្រះអាទិត្យ ដូចជា៖

១.**មករ សន្ក្ករន្ទិ** (Makara Sankaranthi) ជាពិធីដ៏ទូលំទូលាយមួយដែលគេធ្វើឧទ្ទិសដល់ព្រះអាទិត្យ ដោយការអរគុណដល់ព្រះអាទិត្យសម្រាប់ការផ្តល់នូវការប្រមូលផលដ៏ប្រសើរ និងថ្វាយផលដំបូងនោះដល់ព្រះអាទិត្យ។

២. **ឈឋ** (Chhath) ជាពិធីបែបហិណ្ឌូសាសនាមួយទៀតឧទ្ទិសដល់ព្រះអាទិត្យ។ វាចាប់ផ្តើមជាមួយនិង **កំន** (Karna) ជាបុត្រារបស់ព្រះសូរិយាដែលបានក្លាយជាវីរជនប្រយុទ្ធប្រឆាំងជាមួយនិងពួកបន្ឌវ (Pandava) ក្នុងសង្គ្រាមនៅកុរុក្សេត្រា។

៣. **សម្ប ទសមិ** (Samba Dashami) ជាពិធីបុណ្យមួយដែលគេប្រារព្ធនៅរដ្ឋកោះខាងកើតនៃប្រទេសឥណ្ឌា នៅក្នុងការគោរពនៃសម្ប ជាកូនរបស់ក្រឹស្ណៈ ដែលត្រូវបានព្យាបាលរោគឃ្លង់ដោយការបន់ស្រន់ដល់ព្រះសូរិយា។

៤. **រថ សប្តមិ** (Ratha Saptmi) ជាពិធីបែបហិណ្ឌូដែលប្រព្រឹត្តិទៅក្នុងថ្ងៃទី៧កើត (សប្តមិ) នៃខែមាឃរបស់ហិណ្ឌូសាសនា គឺខែកុម្ភៈ ឬមីនា។ ថ្ងៃនោះត្រូវបានគេហៅថា សូរិយា ជយន្ទិ ពីព្រោះវាត្រូវបានគេប្រារព្ធដល់កំលាំងនៃព្រះអាទិត្យដែលគេជឿថាជាផ្នែកមួយ (អវតារ) របស់ទេពវិស្ណុ។ វាជាពិធីបុណ្យទាក់ទងនិងថ្ងៃកំណើតរបស់ព្រះអាទិត្យ/សូរ្យ។[៧]

### តើទំនៀម ឬពិធីទាំងនេះមាននៅក្នុងសង្គមខ្មែរឬទេ?

ប្រពៃណី ឬទំនៀមខាងលើនេះហាក់បីដូចជាពុំមាននៅក្នុងសង្គមខ្មែរសោះ។ ពុំមានសិលាចារឹកណាមួយបង្ហាញអំពីការប្រតិបត្តិលើការសំពះព្រះអាទិត្យនោះទេ។ ក្នុងសិលាចារឹកមួយចំនួនបង្ហាញពី **អាទិត្យ** ត្រឹមតែជាថ្ងៃ១ក្នុងចំណោមថ្ងៃទាំង៧ ដែលគេហៅថា **អាទិត្យវារ** ឧទាហរណ៍សិលាចារឹក K.351។[៨] សិលាចារឹកមួយផ្សេងទៀត K.134[៩] បង្ហាញពីស្ត្រីម្នាក់ដែលមានឈ្មោះហៅថា **អមេ អាទិត្យគំម** ដែលមានន័យថា **ការពារ**

---

[៦] https://www.thehindu.com/society

[៧] https://srikakulam.ap.gov.in/festival/ratha-saptami-festival

[៨] Cœdès, G. (1954:191)

[៩] Cœdès, G. (1942:93)

***ដោយព្រះអាទិត្យ។***[១០] បើយើងមើលលើសំណង់ប្រាសាទខ្លះ ដូចជាអង្គរវត្ត ព្រះបរមរាជវាំងអង្គរធំ គឺបង្ហាញពីការគោរពលើព្រះអាទិត្យ ពិសេសគឺដំណើរគោចរក្នុងរយៈពេល១ឆ្នាំ។ ចំនុចខ្លះក៏យើងអាចយកមកវិភាគអំពីពិធីនេះដែរ។

១.ក្នុងជំនឿហិណ្ឌូសាសនា គេគិតថាព្រះអាទិត្យមានកំណើតពីព្រះវិស្ណុ ដូចពិធី**រថសប្តមិ** ជាពិធីសំពះរំលឹកដល់កំណើតរបស់ពញរះអាទិត្យ ជាពេលវេលាត្រូវនិងខែមាឃប្រហាក់ប្រហែលទៅនិងពេលវេលាសមរាត្រីនៅលើកំពូលកណ្តាលរបស់ប្រាសាទអង្គរវត្តដែរ។ ជាសម្មតិកម្ម ព្រះបាទសូរ្យវរ្ម័នទី២អាចជ្រើសរើសយកពេលសមរាត្រីក្នុងខែមាឃនិងខែភទ្របទ (ជាពេលវេលាដែលព្រះអាទិត្យរះជួបចំកន្ទៀងដដែលក្នុងមួយឆ្នាំ) ធ្វើពិធីសំពះព្រះអាទិត្យ។

២. ព្រះបាទជ័យវរ្ម័នទី៧ ក៏មានព្រះទ័យស្មោះស្ម័គ្រនិងហិណ្ឌូសាសនាដែរ។ ព្រះអង្គអាចគោរព និងសំពះព្រះអាទិត្យ តាមរយៈរូបភាពជាព្រះវិស្ណុ ពីព្រោះព្រះវិស្ណុ និងព្រះអាទិត្យគឺតែមួយ។ នៅប្រាសាទបាយ័ន្ត មានចម្លាក់មួយនៅលើថែវខាងជើង ស្លាបខាងកើត (ថែវខាងក្នុង) បង្ហាញពីសកម្មភាពរបស់ព្រះបាទជ័យវរ្ម័នទី៧ក្រាបសំពះដល់ព្រះបដិមាវិស្ណុ (រូបលេខ១)។

៣. ក្នុងខែមាឃ ប្រជាជនខ្មែរតាមជនបទតែងប្រារព្ធពិធីមួយហៅថា ឡើងមាឃ ដែលពិធីនេះគេធ្វើឡើងដើម្បីរំលឹកដល់គុណធម្មជាតិ ដែលបានផ្តល់ភោគផលនានាដល់ពួកគេ។ នៅក្នុងគំនិតសព្វថ្ងៃ គេតែងធ្វើពិធីថ្វាយដល់អ្នកតាដែលនៅរក្សាភូមិស្រុករបស់គេ។ ប៉ុន្តែបើយើងពិនិត្យមើលឱ្យបានជ្រៅ យើងឃើញថា អ្នកតានោះគឺទាក់ទងទៅនឹងអ្វីដែលជាអធិធម្មជាតិ មានទឹក ដី ភ្លើង ខ្យល់ គឺជាអ្វីដែលបានមកពីកំលាំងនៃព្រះអាទិត្យទាំងអស់។

## ប្រពៃណីដែលអាចមានលក្ខណៈក្លាយ

ចំនុចនេះ យើងអាចសង្កេតមើលក្នុងសង្គមខ្មែរបច្ចុប្បន្ន និងតាមតំបន់មួយចំនួនមិនជាទូទៅនោះទេ។ វាអាចជាជំនឿមួយបែបក្នុងការ សំពះព្រះអាទិត្យ ដើម្បីសុំនូវភាពចំ

[១០] Pou. Saveros, (1992:31)

រុងចំរើន ការលូតលាស់ និងដំណើរទៅគោលដៅមួយៗ ទោះពុំមានភស្តុតាងច្រើន តែមានចំនុច៣ដែលយើងគួរចាប់ផ្តើមសិក្សា និងពិចារណា។

**ក. ការយកទារកទើបនិងកើតទទួលពន្លឺព្រះអាទិត្យ**

ជាការពិតណាស់ ចំនុចនេះមើលទៅហាក់បីដូចជាត្រឹមតែទង្វើរបស់ឱពុកម្តាយ ឬយាយតា ដែលយកកូនឬចៅមកទទួលពន្លឺព្រះអាទិត្យ ដើម្បីទទួលនូវជាតិវីតាមីន ការធ្វើឱ្យភ្នែកនិងស្បែកសាំងនិងពន្លឺនិងកំដៅ និងថាមពលសម្រាប់ការលូតលាស់ (រូបលេខ២៣)។ សព្វថ្ងៃ គេគ្រាន់តែបីទារកចេញមកក្រៅផ្ទះ ឈរទទួលពន្លឺព្រះអាទិត្យរះនៅពេលព្រឹកព្រលឹម ក្នុងរយៈពេល១០ទៅ១៥នាទី ហើយក្នុងរយៈពេល១ទៅ២សប្តាហ៍។ តាមការចងចាំរបស់ចាស់ៗនៅភូមិនគរក្រៅ (សៀមរាប) កាលពីដើម នៅថ្ងៃដំបូង គេរៀបចំធូបទៀន បារីម្លូស្លា និងផ្លែឈើបន្តិចបន្តួច ដាក់សំពះទៅរកព្រះអាទិត្យរះ ដោយមានការនិយាយបួងសួងសុំសេចក្តីសុខ និងការរីកលូតលាស់របស់ទារក។

**ខ.ការសំពះព្រះអាទិត្យក្នុងពិធីអាពាហ៍ពិពាហ៍**

ការសំពះព្រះអាទិត្យក្នុងពិធីអាពាហ៍ពិពាហ៍អាចជាពិធីមួយក្នុងហិណ្ឌូសាសនា។ ពិធីនេះមាននៅតាមតំបន់ខ្លះៗ ពិសេសក្នុងខេត្តសៀមរាប ដែលគេតែងប្រារព្ធធ្វើនៅព្រឹកព្រលឹម មុនព្រះអាទិត្យរះ ក្នុងថ្ងៃទី២នៃពិធីអាពាហ៍ពិពាហ៍ (រូបលេខ២៤)។ គោលបំណងសំខាន់នៃពិធីនេះគឺការកូនកំលោះនិងកូនក្រមុំសុំខមាលទោសពីព្រះអាទិត្យនូវទង្វើទាំងឡាយណាដែលជាកំហុសត្តងដល់ព្រះអាទិត្យ ទេពនិករទាំងឡាយ និងធម្មជាតិ។ ចុងក្រោយគឺការសុំប្រទានពរពីព្រះអាទិត្យដល់គូស្វាមីភរិយាថ្មី។

**គ.ក្នុងពិធីបុណ្យសព**

ក្នុងតំបន់មួយចំនួនដែលមានអាចារ្យយោគីចេះដឹងបន្តពីបុរាណ គេតែងធ្វើទង់ព្រលឹងឱ្យសពដោយមានការគូររូបព្រះអាទិត្យ និងព្រះចន្ទ្រ។ នៅលើទង់នោះក៏មានឈ្មោះបុគ្គលដែលស្លាប់ដែរ វាជាវត្ថុតំណាងឱ្យការនាំផ្លូវព្រលឹងអ្នកស្លាប់បានទៅដល់ទីដៅមួយៗ ក្រោយពេលអាចារ្យធ្វើរួចរាល់ហើយ អាចារ្យតែងយកទៅដាក់លើក្បាលសព ហើយនិយាយទៅកាន់សពឱ្យនាំយកទង់នោះធ្វើដំណើរទៅកាន់ឋានរបស់ព្រះសក្យមុនីចេតិយ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺអាចារ្យឱ្យសំពះគោរពលើព្រអាទិត្យ និងព្រះ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ចន្ទ្រ ព្រោះជាទេពនៃពន្លឺដែលអាចបង្ហាញផ្លូវធ្វើដំណើរបាន។ បើពុំមានព្រះអាទិត្យនិងព្រះចន្ទ្រ នោះព្រលឹងខ្មោចនិងវង្វេងដោយសារភាពងងឹត (រូបលេខ២៤)។

អត្ថបទនេះគ្រាន់តែជាការចាប់ផ្តើម និងសាកល្បងសិក្សាមើលលើចំនុចខ្លះ ព្រោះយើងមិនទាន់មានភស្តុតាងច្រើនសម្រាប់សិក្សាអំពីជំនឿបែបនេះក្នុងសង្គមខ្មែរបុរាណនិងបច្ចុប្បន្ននោះទេ។ ខ្ញុំនិងខិតខំស្រាវជ្រាវបន្ថែម ដើម្បីឱ្យការសិក្សានេះមានភាពទូលំទូលាយ។



រូបលេខ២១



រូបលេខ២២



រូបលេខ២៣



កែវ សុវណ្ណារ៉ា

រូបលេខ២៤



រូបលេខ២៥

## ឯកសារយោង


*សុខ កែវ សុវណ្ណារ៉ា*, (២០២១), *ជំនឿលើព្រះអាទិត្យក្នុងសង្គមខ្មែរ*, ក្នុងAMS , ភ្នំពេញ។

Cœdès, G. (1954:191). *Inscription du Cambodge*, Volume VI, Paris.

Cœdès, G. (1942:93). *Inscription du Cambodge*, Volume II, Hanoi.

https://www.dnaindia.com/india/photo-gallery-chhath-puja

https://en.wikipedia.org/wiki/Surya

https://www.indiatvnews.com/lifestyle/news-chhath

https://www.thehindu.com/society


អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

https://srikakulam.ap.gov.in/festival/ratha-saptami-festival

Pou. Saveros, (1992:31). *An Old Khmer-French-English Dictionary*, Cedoreck, Paris.

W. J. Wilkins, (1882:25) *Hindu Mythology-Vedic and Puranas*, London Missionary Society, Calcutta.

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា